**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.៩៨៩......សហវ.ប្រក

## ប្រកាស

## ស្តីពី

## ការកែសម្រួលសមាសភាពក្រុមការងារប្រព័ន្ធស្វ័យប្រវត្តិកម្មគយ

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ១៣៩៧ សហវ.ប្រក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធស្វ័យប្រវត្តិកម្មគយ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom, Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

## សម្រេច

**ប្រការ ១.-**

ត្រូវបានកែសម្រួលសមាសភាព "ក្រុមការងារប្រព័ន្ធស្វ័យប្រវត្តិកម្មគយ" ដូចខាងក្រោម÷

| | | |
|---|---|---|
| ១. លោក **ផា អេងទើង** | ប្រធាននាយកដ្ឋានរបបគយ | ប្រធាន |
| ២. លោក **ជួន ចំន្ទសោភា** | ប្រធានការិយាល័យស្ថិតិនិងប្រព័ន្ធព័ត៌មានវិទ្យា | អនុប្រធាន |
| ៣. លោក **ណាយ សុផាន់ណារិទ្ធ** | ភ្នាក់ងារសាខាគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ | សមាជិក |
| ៤. លោក **មឿន សុភក្ដី** | ភ្នាក់ងារសាខាគយនិងរដ្ឋាករខេត្តកំពង់ឆ្នាំង | សមាជិក |
| ៥. លោក **សាន ចំរើន** | ភ្នាក់ងារសាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ | សមាជិក |
| ៦. លោក **ផាន់ តារិទ្ធ** | ភ្នាក់ងារសាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិភ្នំពេញ | សមាជិក |
| ៧. លោក **ទ៉ាន់ ទុធថា** | ភ្នាក់ងារនាយកដ្ឋានបង្ការ និងបង្ក្រាបបទល្មើស | សមាជិក |
| ៨. លោក **អ៊ីង ទីសាល** | ភ្នាក់ងារការិយាល័យគយនិងរដ្ឋាករខណ្ឌចំការមន | សមាជិក |
| ៩. លោក **ខន សុភារិន្ទ** | អ្នកជំនាញក្នុងស្រុកជាប់កិច្ចសន្យា | សមាជិក |
| ១០. លោក **ហេង សុធារិទ្ធ** | អ្នកជំនាញក្នុងស្រុកជាប់កិច្ចសន្យា | សមាជិក |
| ១១. លោក **សុខ តារិន** | អ្នកជំនាញក្នុងស្រុកជាប់កិច្ចសន្យា | សមាជិក |
| ១២. លោក **ឃាម ហាក់ស្រ៊ុន** | អ្នកជំនាញក្នុងស្រុកជាប់កិច្ចសន្យា | សមាជិក |
| ១៣. លោក **សិទ្ធ ចាន់វត្ថា** | អ្នកជំនាញក្នុងស្រុកជាប់កិច្ចសន្យា | សមាជិក |
| ១៤. លោក **ឆន ទិត្យ** | អ្នកជំនាញក្នុងស្រុកជាប់កិច្ចសន្យា | សមាជិក |

**ប្រការ ២.-**

ក្រុមការងារប្រព័ន្ធស្វ័យប្រវត្តិកម្មគយមានតួនាទី និងភារកិច្ចដូចតទៅ ÷

- គ្រប់គ្រងថែរក្សាហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធកុំព្យូទ័រមេ និងប្រព័ន្ធកុំព្យូទ័រមេសម្រាប់ជំនួសក្នុងករណីប្រធានស័ក្តិ
- ធានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងនិរន្តរភាពនៃកិច្ចប្រតិបត្តិការប្រព័ន្ធប្រចាំថ្ងៃ និងការធ្វើបច្ចុប្បន្នភាពនានានៃប្រព័ន្ធ
- គ្រប់គ្រង ពិគ្រោះនិងផ្តល់យោបល់ដល់គ្រប់នាយកដ្ឋាន សាខានិងការិយាល័យគយនិងរដ្ឋាករទាំងអស់ដែលប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មគយ នូវការងារដែលពាក់ព័ន្ធនឹងការអនុវត្តប្រព័ន្ធ និងអញ្ជើញមន្ត្រីគយនិងរដ្ឋាករពាក់ព័ន្ធឲ្យចូលរួមប្រជុំតាមការចាំបាច់
- គ្រប់គ្រង តាមដាននិងធ្វើសវនកម្មលើកិច្ចប្រតិបត្តិការប្រព័ន្ធស្វ័យប្រវត្តិកម្មគយ នៅអង្គភាពថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋានក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

- សិក្សាវាយតម្លៃពីប្រសិទ្ធភាព និងពិនិត្យលទ្ធភាពពង្រីកមុខងារប្រព័ន្ធនិងវិសាលភាពភូមិសាស្ត្រ ដើម្បីឈានទៅសម្រេចបានការអនុវត្តពេញលេញប្រព័ន្ធស្វ័យប្រវត្តិកម្មគយ
- ទំនាក់ទំនង និងពិភាក្សាការងារក្នុងកម្រិតបច្ចេកទេសជាមួយដៃគូអភិវឌ្ឍ និងផ្នែកឯកជននានាពាក់ព័ន្ធនឹងការអនុវត្តប្រព័ន្ធ
- បែងចែកការងារ និងភារកិច្ចទទួលខុសត្រូវទៅតាមផ្នែក ជំនាញ និងបទពិសោធន៍ជាក់ស្តែង
- ធ្វើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តប្រព័ន្ធ ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- មានសិទ្ធិស្នើសុំមន្ត្រីគយនិងរដ្ឋាករផ្សេងទៀតដើម្បីចូលរួមសហការ និងអនុវត្តការងារតាមតម្រូវការចាំបាច់
- មន្ត្រីគយនិងរដ្ឋាករដែលជាសមាជិកក្រុមការងារត្រូវបំពេញភារកិច្ចតាមបញ្ញត្តិនៃប្រកាសនេះ បន្ថែមលើមុខងារស្នូលបច្ចុប្បន្ន និងត្រូវមកបំពេញការងារពេញម៉ោងនៅការិយាល័យកណ្តាលនៃប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និងអនុវត្តភារកិច្ចផ្សេងទៀតតាមការកំណត់របស់អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**ប្រការ ៣.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អាចធ្វើការកែសម្រួលសមាសភាពមន្ត្រីគយនិងរដ្ឋាករដែលជាសមាជិកក្រុមការងារ និងជ្រើសរើសអ្នកជំនាញព័ត៌មានវិទ្យាក្នុងស្រុកជាប់កិច្ចសន្យាបន្ថែមតាមតម្រូវការចាំបាច់។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាល អគ្គនាយក ប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ ២០១៦

អូន ព័ន្ធមុនីរ័ត្ន

**<u>កន្លែងទទួល</u>** ÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេច ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- គ្រប់សាលារាជធានី-ខេត្តពាក់ព័ន្ធ
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ